Bona Neary shared Sourn Serey Ratha's post.

Yesterday at 8:43am ·

ថ្ងៃទី ៤ មិថុនា ២០១៦,

ខ្ញុំ ជាកូនខ្មែរក្រោម កើតនៅទឹកដីខ្មែរកណ្ដាល ។ ខ្ញុំ ថ្កោលទោសពួកអ្នកធ្វើបុណ្យរំលឹកខួបបាត់បង់ទឹកដីកម្ពុជាក្រោម ពីព្រោះបើ កូនខ្មែរឬខ្មែរក្រោមនាំគ្នាធ្វើបុណ្យខួបបាត់បង់ទឹកដី គឺមានន័យស្មើនឹងទទួលស្គាល់ថា ទឹកដីកម្ពុជាក្រោមបាត់បង់ហើយ !

តែខ្ញុំ ដូនតាខ្ញុំ និងគ្រួសាររបស់ខ្ញុំ គ្រប់ជំនាន់ យើងមិនដែលទទួលស្គាល់ថា ទឹកដីកម្ពុជាក្រោមបាត់បង់ទេ គឺយើងតែងប្រកាសបន្តជំនាន់ថា យួនឈ្លានពានយកទឹកដីកម្ពុជាក្រោម ទៅត្រួតត្រាដោយរំលោភសិទ្ធិខ្មែរក្រោមម្ចាស់ដី ។ ហើយដូនតាខ្ញុំគ្រប់ជំនាន់ ផ្ដាំពួកខ្ញុំថា យើងខ្មែរក្រោម យើងបាត់បង់តែសិទ្ធិអំណាចគ្រប់គ្រងដែនដីកម្ពុជាក្រោមប៉ុណ្ណោះ តែយើងដាច់ខាតមិនត្រូវទទួលស្គាល់ថា យើងបាត់បង់ទឹកដីទេ ។ តាំងពីឆ្នាំ ១៩២០ ដែលជីតាខ្ញុំ កាន់ដាវ កាន់ដំបងប្រឆាំងយួនឈ្លានពានទឹកដី រហូតដល់ឆ្នាំ ១៩៩២ មុនពេលជីតាខ្ញុំស្លាប់ គាត់ផ្ដាំកូនៗ និងចៅថា យើងខ្មែរក្រោមបាត់បង់សិទ្ធិអំណាចគ្រប់គ្រងទឹកដីមែន តែសិទ្ធិនិងអំណាចម្ចាស់ដីនេះ យើងនឹងអាចទាមទារយកមកវិញបាននៅថ្ងៃណាមួយខាងមុខមិនខាន...កូនៗ និងចៅៗ ខ្មែរក្រោមយើង ដាច់ខាតមិនត្រូវទទួលស្គាល់ថា យើងបាត់បង់ទឹកដីកម្ពុជាក្រោមទេ ហើយក៏មិនត្រូវធ្វើបុណ្យ ឬធ្វើខួប បាត់បង់ទឹកដី តាមបំណងយួនចង់បាននោះដែរ ។ បើកូនៗ ចៅៗធ្វើបុណ្យខួបបាត់បង់ទឹកដីកម្ពុជាក្រោម គឺដូចកូនៗ ចៅ ធ្វើបុណ្យខួបបាត់បង់ឪ និងបាត់បង់តា ដែលមានន័យថា ឪ និងតាស្លាប់ហើយ មិនអាចរស់វិញបានទេ ។ បើមានឱកាស ចៅត្រូវនាំខ្មែរក្រោម ធ្វើទិវាចងកំហឹងរំលឹកថ្ងៃខ្មែរក្រោម បាត់បង់សិទ្ធិគ្រប់គ្រងទឹកដីកម្ពុជាក្រោម (ជីតាខ្ញុំ និយាយមកកាន់ខ្ញុំ និងចៅៗ) ហើយត្រូវនាំគ្នាទាមទារសិទ្ធិដែលបាត់បង់នេះ យកមកវិញ តែដាច់ខាតមិនត្រូវចូលរួម ឬធ្វើបុណ្យបាត់បង់ទឹកដីទេ ។

បណ្ដាំដូនតា ត្រូវតែសម្រេចឲ្យបាន... មុននឹងឈានទៅដល់ការរំដោះសេរីភាពខ្មែរក្រោមរាប់លាននាក់ដែលកំពុងរស់នៅក្រោមអាណានិគមន៍យួន ថ្ងៃនេះខ្ញុំដឹកនាំ គណបក្សអំណាចខ្មែរ ខ្ញុំប្រកាសមិនទទួលស្គាល់ពួកអ្នកធ្វើបុណ្យខួបបាត់បង់ទឹកដីកម្ពុជាក្រោមទេ ហើយខ្ញុំប្រកាសថា ថ្ងៃនេះ (៤ មិថុនា) ជាថ្ងៃនៃ « ទិវាចងកំហឹង រំលឹកថ្ងៃខ្មែរក្រោមបាត់បង់សិទ្ធិគ្រប់គ្រងទឹកដី» ៕